ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ:៥៨៥/១១-០៧-២០១១
សាលដីកា
លេខ:១៣ ក្រ.ក/០៥-៣-២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៤ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ៥៨៥ចុះថ្ងៃទី១១-០៧-២០១១ រវាង:

១-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនសាន ហៅហេង ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ កើតនៅស្រុកក្រចេះ ខេត្តក្រចេះ ទីលំនៅមុនឃាត់ខ្លួន [redacted] ឪពុកឈ្មោះ [redacted](រ) ម្ដាយឈ្មោះ [redacted](រ) ទោសពីមុនគ្មាន (ជាដើមបណ្ដឹងឧទ្ធរណ៍) ។

-ឃុំខ្លួនថ្ងៃទី៣១-៧-២០១០ ។

-មេធាវី លោក [redacted] វ៉ាន់ឈាន និងមេធាវី [redacted] ហៃ ។

ត្រូវចោទពីបទ ជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ប្រព្រឹត្តនៅហាងកាហ្វេយូរអេនមី ផ្លូវលេខ១៧២ សង្កាត់អូរឬស្សី៣ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៣ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ឈ្មោះ [redacted] ថា ភេទស្រី អាយុ៥៨ឆ្នាំ ជនជាតិវៀតណាម មុខរបរលក់ខោអាវជជុះ កើតនៅស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ទីលំនៅសព្វថ្ងៃផ្ទះ [redacted] /ៗ

៧១





Scanned with CamScanner

[redacted] ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (ស) ប្ដីឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន (ជាដើមបណ្ដឹងឧទ្ធរណ៍) ។

-ឃុំខ្លួនថ្ងៃទី៣១-៧-២០១០

-មេធាវី លោក [redacted] ចន្ថា

៣-ឈ្មោះ [redacted] សុវណ្ណារ៉ា ហៅស្រួយ ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរបើកហាងខាត់អ្វខេ កើតនៅទីរួមខេត្តស្វាយរៀង ទីលំនៅមុនឃាត់ខ្លួន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន ។ ឃុំខ្លួនថ្ងៃទី៣១-៧-២០១០ (ជាដើមបណ្ដឹងឧទ្ធរណ៍) ។

-មេធាវីលោក [redacted] អៀវហេង ។

ត្រូវចោទពីបទ៖ ជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ និងផលិតគ្រឿងញៀនដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដោយខុសច្បាប់ ប្រព្រឹត្តនៅផ្ទះលេខ៦២បេ ផ្លូវលេខ៣៨៦ សង្កាត់បឹងកេងកង ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០១០ ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា៣៣ថ្មី និងមាត្រា៣២.១ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤-ឈ្មោះ [redacted] គឹមង៉ុក ភេទស្រី អាយុ១៦ឆ្នាំ ជនជាតិវៀតណាម មុខរបរលក់ដូរ កើតនៅស្រុកតៃនិញ ប្រទេសវៀតណាម ទីលំនៅមុនឃាត់ខ្លួន [redacted] ឪពុកមិនស្គាល់ឈ្មោះ ម្ដាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី៣១-៧-២០១០ (ជាដើមបណ្ដឹងរដ្ឋប្បវេណី) ។

-មេធាវីលោក [redacted] ចន្ថា ។

អ្នកបកប្រែភាសាវៀតណាម លោក [redacted] សេង

ត្រូវចោទពីបទ៖ សមគំនិតក្នុងអំពើជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ និងផលិតគ្រឿងញៀន ដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដោយខុសច្បាប់ ប្រព្រឹត្តនៅផ្ទះលេខ៦២បេ ផ្លូវលេខ៣៨៦ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០១០ ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៣ថ្មី, មាត្រា៣២.១ថ្មី និងមាត្រា៤៣នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនខុសច្បាប់ ។

## ៦រឿងហេតុមានដូចតទៅ៖

តាមរបាយការណ៍របស់សមត្ថកិច្ចបញ្ជាក់ថា៖

នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១០ ឈ្មោះ [redacted] ម៉េង បានទំនាក់ទំនងរកស៊ីគ្រឿងញៀនតាមរយៈឈ្មោះ [redacted] ប៊ុនសាន ហៅហេង ហើយឈ្មោះនេះបានទំនាក់ទំនងជាមួយឈ្មោះហាយ (បងរបស់ឈ្មោះឡេងជាមិត្តភក្ដិរបស់ខ្លួន) ដោយកំណត់តម្លៃគ្រឿងញៀនប្រភេទគ្រាប់(MDMA) ក្នុងមួយគ្រាប់តម្លៃប្រាំមួយដុល្លាអាមេរិកតម្លៃទិញ ហើយឈ្មោះ [redacted] ប៊ុនសាន លក់ចេញវិញមួយគ្រាប់តម្លៃ៨ដុល្លាអាមេរិក និងកំណត់ទទួលលុយមុន ទើបប្រគល់គ្រឿងញៀនតាមក្រោយ ។ ឈ្មោះ [redacted] ប៊ុនសាន និងឈ្មោះ [redacted] ម៉េង កំណត់ថ្ងៃប្រគល់ទទួលគ្រឿងញៀននៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០ នៅហាងកាហ្វេយូអេនមី ស្ថិតនៅផ្លូវលេខ១៧២ សង្កាត់អូរឬស្សី៣

ខណ្ឌ៧មករា ។ នៅព្រឹកថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០ វេលាម៉ោង១២និង០០នាទី ថ្ងៃត្រង់ ឈ្មោះ [redacted] ម៉េង បាននាំអ្នកទិញគ្រឿងញៀនទៅជួបឈ្មោះ [redacted] ប៊ុនសាន នៅហាងកាហ្វេយូអេនមី ហើយឈ្មោះ [redacted] ប៊ុនសាន បានទទួលលុយចំនួន៨០០០ដុល្លាអាមេរិក (ប្រាំបីពាន់ដុល្លាអាមេរិក) យកទៅទិញគ្រឿងញៀននៅផ្ទះលេខ៦២បេ ផ្លូវលេខ៣៨៦ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមានឈ្មោះ [redacted] ថា បើកទ្វារផ្ទះឲ្យ និងបានទទួលគ្រឿងញៀនពីឈ្មោះហាយ រួចចេញមកវិញ ដោយឈ្មោះ [redacted] ថា ជាអ្នកបិទទ្វារផ្ទះ រួចយកមកប្រគល់ឲ្យអ្នកទិញនៅហាងកាហ្វេ ក៏ត្រូវសមត្ថកិច្ចបង្ក្រាបឃាត់ខ្លួនឈ្មោះ [redacted] ប៊ុនសាន និងឈ្មោះ [redacted] ម៉េង ដកហូតបានថ្នាំមេតំហ្វេតាមីនចំនួន១០០គ្រាប់ស្មើ២៨,៦០g បន្ទាប់មកសមត្ថកិច្ចឲ្យឈ្មោះ [redacted] ប៊ុនសាន នាំទៅចង្អុលផ្ទះដែលខ្លួនយកថ្នាំមកលក់ ក៏បានឃាត់ខ្លួនមនុស្សថែម៣នាក់ និងដកហូតបានគ្រឿងញៀនមេតំហ្វេតាមីន (ICE) ចំនួន៣ថង់ស្មើនឹង៩៥.៨០ក្រាម, ហេរ៉ូអ៊ីនចំនួន១ថង់ទម្ងន់ ២៧ក្រាម គ្រឿងញៀនប្រភេទគ្រាប់ (MDMA) ចំនួន៨៧៥គ្រាប់ ស្មើនឹង១០៧.៩០ក្រាម កញ្ឆាកិនចំនួន ១ថង់ ស្មើ២៣២ក្រាម ម្សៅពណ៌សសំរាប់លាយទម្ងន់៨៨២.៦០ក្រាម ថ្នាំគ្រាប់រាងទ្រវែងទម្ងន់ ២៨១.៧៥ក្រាម ឧបករណ៍ពុម្ពសំរាប់ផលិតកែច្នៃគ្រឿងញៀនមួយចំនួន ប្រាក់ចំនួន១៦៣០០ដុល្លាអាមេរិក (មួយម៉ឺនប្រាំមួយពាន់បីរយដុល្លាអាមេរិក) រថយន្តមួយគ្រឿងម៉ាកLexus RX300 មួយគ្រឿង ទោចក្រយានយន្តចំនួន៣គ្រឿងរួមនិងសំភារៈមួយចំនួនទៀត រីឯគូកនជនល្មើសឈ្មោះ ហាយ, ឈ្មោះ ធី, ឈ្មោះ ង៉ៀង រត់គេចខ្លួន មុនពេលសមត្ថកិច្ចចុះទៅបង្ក្រាប ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២៨ ក្រ១ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារសេចក្តីសម្រេចដូចតទៅ៖

១-ឲ្យឈ្មោះ [redacted] ម៉េង ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ រួចខ្លួនពីបទ ជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅចំណុចហាងកាហ្វេយូអេនមី ផ្លូវលេខ១៧២ សង្កាត់អូរឬស្សី៣ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០ តាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនិងមាត្រា៥៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

២-ផ្តន្ទាទោស

ក-ឈ្មោះ [redacted] ប៊ុនសាន ហៅហេង ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល១០ឆ្នាំ (ដប់ឆ្នាំ) និងពិន័យជាប្រាក់ចំនួន ២០.០០០.០០០រៀល (ម្ភៃលានរៀល) ។

ពីបទ ជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅចំណុចហាងកាហ្វេយូអេនមី ផ្លូវលេខ១៧២ សង្កាត់អូរឬស្សី៣ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនខុសច្បាប់ ។

ខ-ឈ្មោះ [redacted] ថា ភេទស្រី អាយុ៤៨ឆ្នាំ ជាតិវៀតណាម ដាក់ពន្ធនាគារកំណត់រយៈពេល១២ឆ្នាំ (ដប់ពីរឆ្នាំ) និងពិន័យជាប្រាក់ចំនួន២០.០០០.០០០រៀល (ម្ភៃលានរៀល) ។

គ-ឈ្មោះ [redacted] សុវណ្ណារ៉ា ហៅស្រួយ -ភេទប្រុស អាយុ៥០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល១០ឆ្នាំ (ដប់ឆ្នាំ) និងពិន័យជាប្រាក់ម្នាក់ចំនួន ២០.០០០.០០០រៀល (ម្ភៃលានរៀល) ។/។



Scanned with CamScanner

ពីបទ ជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ និងផលិតគ្រឿងញៀនដែលបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដោយខុសច្បាប់ ប្រព្រឹត្តនៅផ្ទះលេខ៦២បេ ផ្លូវលេខ៣៨៦ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០១០ ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០ តាមមាត្រា៣៣ថ្មី និងមាត្រា៣២.១ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ឃ-ឈ្មោះ [redacted] គឹមង៉ុក ភេទស្រី អាយុ១៦ឆ្នាំ ជាតិវៀតណាម ដាក់ពន្ធនាគារកំណត់រយៈពេល០៦ឆ្នាំ (ប្រាំមួយឆ្នាំ) និងពិន័យជាប្រាក់ចំនួន១០.០០០.០០០រៀល (ដប់លានរៀល) ។

ពីបទ សមគំនិតក្នុងអំពើជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ និងផលិតគ្រឿងញៀនដែលបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដោយខុសច្បាប់ ប្រព្រឹត្តនៅផ្ទះលេខ៦២បេ ផ្លូវលេខ៣៨៦ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០១០ ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០ តាមមាត្រា៣៣ថ្មី និងមាត្រា៣២.១ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-វត្ថុតាងរួមមានៈ

ក-ស្រោមសំបុត្របិទជិត (ត្លុំបេ) ពណ៌គគី មានចុះហត្ថលេខាសមត្ថកិច្ចឈ្មោះ សៀង ណុល ឈ្មោះ ម៉ែន ណុល ឈ្មោះ ចាប សាម៉េង និងបោះត្រាមន្ទីរប្រឆាំងគ្រឿងញៀន និងស្នាមមេដៃឈ្មោះ [redacted]ប៊ុនសាន ។

-ស្រោមសំបុត្រពណ៌គគីធំបិទជិត (ត្លុំបេ) មានចុះហត្ថលេខាសមត្ថកិច្ចឈ្មោះ សៀង ណុល ឈ្មោះ ម៉ែន ណុល ឈ្មោះ ចាប សាម៉េង បោះត្រាមន្ទីរប្រឆាំងគ្រឿងញៀន និងស្នាមមេដៃឈ្មោះ THA ឈ្មោះ RA ឈ្មោះ NGOC

-ដែកគ្រីបចំនួន០១ (មួយ) បំពង់កែវសំរាប់ផលិតចំនួន០៣ (បី) ពុម្ពវាយថ្នាំចំនួន១០ (ដប់) និងជើងគ្រីបចំនួន០១ (មួយ) រួមសំភារៈផលិតមួយចំនួន ត្រូវរឹបអូសបំផ្លាញចោល ។

ខ-រថយន្តម៉ាក LEXUS RX300 ពណ៌ស្ករ ពាក់ស្លាកលេខ ភ្នំពេញ ២I ៧៨៩៨ ចំនួន០១គ្រឿង (មួយគ្រឿង)

-ម៉ូតូម៉ាក HONDA AIR BLADE ពាក់ស្លាកលេខ ១W ៥០០៨ ភ្នំពេញ លេខតួនិងលេខម៉ាស៊ីន ១៨០X៧Y៥៣៥៧២០ ចំនួន០១គ្រឿង (មួយគ្រឿង)

-ម៉ូតូម៉ាក CLICK ពាក់ស្លាកលេខ ភ្នំពេញ ១AK ៥៧៧៥ លេខតួនិងលេខម៉ាស៊ីន DM00៦៦៥៧២ ចំនួន០១គ្រឿង (មួយគ្រឿង)

-ទូរទឹកកកម៉ាក HITACHI ចំនួន០១គ្រឿង (មួយគ្រឿង) ម៉ាស៊ីនបោកខោអាវម៉ាក Panasonic ចំនួន០១គ្រឿង (មួយ) ម៉ាញ៉េម៉ាក SONY ចំនួន០១គ្រឿង (មួយ) ឈុត ម៉ាស៊ីតចាក់វីស៊ីឌីម៉ាក Califonia ចំនួន០១គ្រឿង(មួយ) ធុងបាស់តូចចំនួន០៣(បី) ធុងសាប់០១ (មួយ)កូនកង្ហារចំនួន០១(មួយ) ចង្កៀងអំពូលពណ៌ចំនួន០១ (មួយ) ទូរទស្សន៍ម៉ាក SONY ពណ៌ខ្មៅទំហំ២១អ៊ិញចំនួន០១(មួយ) "មិនមានក្នុងកំណត់ហេតុដកហូត"

-ប្រាក់ដុល្លាចំនួន ១៦.៣០០ដុល្លា (មួយម៉ឺនប្រាំមួយពាន់បីរយដុល្លាអាមេរិក)

-ទូរស័ព្ទល្អគា ចំនួន០៣គ្រឿង (បី) និង Wifi Phone ចំនួន០១គ្រឿង (មួយ) ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

គ-លិខិតឆ្លងដែនពណ៌បៃតងចំនួន០១ក្បាល (មួយ) លេខ B1514341



Scanned with CamScanner

-ម៉ូតូម៉ាក HONDA ICON ពាក់ស្លាកលេខ ភ្នំពេញ ១AC ២១១១ លេខតួនិងលេខម៉ាស៊ីន NC១១០CM០០០២២៨៣ ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ។

៨-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ប៊ុនសាន ហៅ ហេង ឈ្មោះ [redacted] ថា ឈ្មោះ [redacted] សុវណ្ណារ៉ា ឈ្មោះ [redacted] គឹមង៉ុក មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ហៃ ឈ្មោះ [redacted] ចន្ថា ឈ្មោះ [redacted] ថេង ឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] កិរិយា កំបាំងមុខ ឈ្មោះ [redacted] ម៉េង បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៦-០៤-២០១១ របស់ឈ្មោះ [redacted] សុវណ្ណារ៉ា, សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១-០៤-២០១១ របស់ឈ្មោះ [redacted] ប៊ុនសាន, សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៥-០៤-២០១១ របស់ឈ្មោះ [redacted] ថា និងសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥-០៤-២០១១ របស់ឈ្មោះ [redacted] គឹមង៉ុក សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៨ ក្រ១ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចសេចក្តីសម្រេចនៃសាលក្រមទាំងមូល ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនសាន បានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុខ្លួនបានទទួលលុយពីគេចំនួន៨.០០០ដុល្លាអាមេរិកទៅទិញគ្រឿងញៀនមែន នៅផ្ទះបងធម៌របស់ឈ្មោះ ឡេង ដែលថ្នាំញៀនគេដាក់ក្នុងស្បោងខ្មៅ រួចខ្លួនយកថ្នាំនោះទៅឲ្យម្ចាស់លុយ ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួន រួមនឹងថ្នាំញៀនប្រហែល១០០គ្រាប់ ។ ឈ្មោះលេងជាមិត្តភក្តិខ្លួន បងធម៌វានៅអូឬស្សីមានថ្នាំញៀន តែខ្លួនមិនស្គាល់ឈ្មោះអ្នកលក់ថ្នាំទេ ព្រោះទើបជួញដូរលើកទី១ ហើយក្នុងផ្ទះនោះមានគ្នា៤ទៅ៥នាក់ តែខ្លួនមិនស្គាល់ទាំងអស់ ។ ពេលចាប់ខ្លួនបានសមត្ថកិច្ចឲ្យខ្លួនបង្ហាញផ្ទះលក់ថ្នាំនោះ តែខ្លួនមិនបានចូលទេ គេឲ្យនៅក្នុងឡាន ។ សំណូមពរសុំបន្ធូរបន្ថយទោស ។

-ជនជាប់ចោទឈ្មោះ [redacted] ថា បានឆ្លើយបញ្ជាក់ថា ខ្លួនជួលផ្ទះរស់នៅមានគ្នា៣នាក់ ផ្ទះនោះមានពីរជាន់ តម្លៃ៣០០ដុល្លា ហើយជាន់ក្រោមបានជួលបន្តឲ្យជនជាតិវៀតណាមឈ្មោះ ង៉ៀង យ៉ាហាយ និងប្រពន្ធគាត់ បានឈ្នួលមួយខែ ៣០០ដុល្លា គឺខ្លួនមិនអស់លុយទេ ហើយក៏គ្មានលិខិតស្នាមដែរ ។ ឈ្មោះ [redacted] យ៉ាហាយ និងប្រពន្ធគាត់ធ្វើការខារ៉ាអូខេពេលយប់ទើបឃើញមកដេក ហើយខ្លួនចេញចូល វៀតណាមមិនសូវនៅផ្ទះទៀងទាត់ទេ និងមិនបានឃើញឈ្មោះហាយ ដាក់ឥវ៉ាន់អ្វីដែរ ព្រោះនៅក្នុងបន្ទប់ ។ ពេលឈ្មោះ [redacted] ប៊ុនសាន មកហៅទ្វារមែន នៅពេលខ្លួនកំពុងរៀបឥវ៉ាន់ទៅវៀតណាម នៅជិតទ្វារស្រាប់តាមច្រកចូលឡើងលើផ្ទះ ហើយខ្លួនមិនដែលទំនាក់ទំនងជាមួយ [redacted] ប៊ុនសាន ទេ។ ឈ្មោះ គឹមង៉ុកមានផ្ទះជួលក្បែរខ្លួនទើបហៅវាមកបោកគក់ខោអាវជជុះ។ ឈ្មោះ [redacted] សុវណ្ណារ៉ា ខ្លួនស្គាល់ហើយរាល់ពេលទៅវៀតណាមបានឲ្យគាត់ជួយរៀបចំនិងជូនឡើងឡាន។ ថ្ងៃដែលសមត្ថកិច្ចចូលឆែកឆេរប្រហែលម៉ោង១២ថ្ងៃ ក្នុងពេលខ្លួនកំពុងរៀបចំខោអាវទៅវៀតណាម ត្រូវដឹកខោអាវជជុះដាក់បេនឡាន តាមរ៉ឺម៉កម៉ូតូកង់បី ឯឈ្មោះ [redacted] សុវណ្ណារ៉ា ជាអ្នកម៉ូតូឌុបជូនខ្លួន ។ សំណូមពរសុំតុលាការដោះលែង ព្រោះខ្លួនមិនបានប្រព្រឹត្ត ។

-ជនជាប់ចោទឈ្មោះ [redacted] គឹមង៉ុក បានឆ្លើយបញ្ជាក់ថា ខ្លួនមានផ្ទះជួលក្បែរផ្ទះឈ្មោះ [redacted] ថា ហើយថ្ងៃកើតហេតុខ្លួននៅផ្ទះ [redacted] ថា ជួយរើសខោអាវជជុះឲ្យគាត់ ជូនកាលគាត់ឲ្យប្រាក់

១ម៉ឺនរៀលទៅ២ម៉ឺនរៀល ហើយឈ្មោះ [redacted] ថា ទៅវៀតណាម២ខែមកម្តង។ ការងារក្រៅពីបោកគក់ខោអាវឲ្យឈ្មោះ [redacted] ថា គឺខ្លួននៅផ្ទះខ្លួនឯង។ ខ្លួនកើតនៅប្រទេសវៀតណាមបានមកស្រុកខ្មែរ៥ឆ្នាំ ទើបចាប់ខ្លួន ហើយប៉ូលីសដកហូតមានទូរសព្ទ័មួយគ្រឿង និងលុយ២ម៉ឺនរៀល ។ សំណូម ពរសុំតុលាការដោះលែង ព្រោះខ្លួនមិនបានប្រព្រឹត្ត ។

-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ា បានឆ្លើយបញ្ជាក់ថា ខ្លួនមានមុខរបរបើកខារ៉ាអូខេ បានស្គាល់ [redacted] ថា ប្រហែលមួយឆ្នាំ គឺគាត់ឧស្សាហ៍ឲ្យជូនគាត់ទៅបេនឡានទៅវៀតណាម ។ នៅថ្ងៃកើតហេតុឈ្មោះ [redacted] ថា បានឲ្យខ្លួនទិញនំប៉័ងឲ្យគាត់និងឌុបគាត់ទៅបេនឡាន ហើយខ្លួនធ្លាប់ឌុបគាត់ពីរ បីដង ព្រោះ២ឬ៣ខែគាត់មកម្តង។ ចម្លើយនៅប៉ូលីសដាក់ឈ្មោះរ៉ា ចំចម្លើយរបស់ខ្លួន ហើយចម្លើយនេះខ្លួនបដិសេធ តែគេនៅតែបង្ខំឲ្យផ្តិតមេដៃ។ សុំតុលាការជួយរកយុត្តិធម៌និងសុំលើកលែងទោស ។

-តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋានៈ

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងពិនិត្យឯកសារពាក់ព័ន្ធក្នុងសំណុំរឿងឃើញថា ជនជាប់ចោទឈ្មោះ [redacted] ប៊ុនសាន បានសារភាពថា បានប្រព្រឹត្តអំពើដូចការចោទប្រកាន់ ដោយបានទទួលប្រាក់៨០០០ដុល្លា (ប្រាំបីពាន់ដុល្លាអាមេរិក) ទៅទិញថ្នាំបាន១០០គ្រាប់យកទៅប្រគល់ឲ្យអ្នកទិញនៅហាងកាហ្វេយូអិនមី ហើយត្រូវបានចាប់ខ្លួននៅទីនោះ ។ ឈ្មោះនេះបានបដិសេធថា មិនបានចូលរួមប្រព្រឹត្តអំពើផលិតថ្នាំញៀនទេ ហើយក៏មិនស្គាល់ឈ្មោះ [redacted] ថា, [redacted] គឹមង៉ុក និង [redacted] សុវណ្ណារ៉ា ដែរ រីឯអ្នកទាំង៣រូបនេះក៏អះអាងថាមិនដែលស្គាល់ឈ្មោះ [redacted] ប៊ុនសាន ដែរ គ្រាន់តែធ្លាប់ឃើញចេញចូលផ្ទះនេះម្តងម្កាល ។ តាមកំណត់ហេតុដកហូតវត្ថុតាងលិខិតកោសល្យវិច្ច័យ សូមក្រុមប្រឹក្សាពិចារណាលើគោលការណ៍ឯកតកម្មនៃទោសដោយឈ្មោះ [redacted] ប៊ុនសាន មានភស្តុតាងដាក់បន្ទុកត្រឹមលក់ថ្នាំញៀន១០០គ្រាប់ ។

ដោយឡែកឈ្មោះ [redacted] ថា និងឈ្មោះ [redacted] សុវណ្ណារ៉ា មានចម្លើយមិនប្រែប្រួល ដែលអះអាងថាមិនស្គាល់ឈ្មោះ [redacted] ប៊ុនសាន ហើយបដិសេធការចោទប្រកាន់ដោយបញ្ជាក់ថា ថ្នាំញៀននិងសំភារៈដែលបានដកហូតជារបស់អ្នកជួលបន្ទប់ពីខ្លួន សូមក្រុមប្រឹក្សាពិចារណា និងសម្រេចតាមច្បាប់ ។ រីឯឈ្មោះ ចុង គឹមង៉ុក ដែលបានកើតនៅវៀតណាម យល់ដឹងភាសាខ្មែរមិនច្បាស់ ហើយចម្លើយនៅសមត្ថកិច្ចរហូតដល់ចៅក្រមស៊ើបសួរ គ្មានអ្នកបកប្រែ ហើយបានបដិសេធការចោទប្រកាន់ដោយអះអាងថា ខ្លួនគ្រាន់ជាអ្នករៀបខោអាវជជុះឲ្យឈ្មោះ [redacted] ថា ដែលចម្លើយនេះមានលក្ខណៈស៊ីសង្វាក់នឹងចម្លើយរបស់ឈ្មោះ [redacted] ថា ដែរ ហេតុនេះសូមក្រុមប្រឹក្សាពិចារណា និងសម្រេចតាមច្បាប់ ។

លោក [redacted] អៀវហេង មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ា សន្និដ្ឋានៈ

ចម្លើយកូនក្តីខ្លួន នៅប៉ូលីសនិងចម្លើយពេលនេះគ្មានប្រែប្រួលទេ ហើយឈ្មោះ [redacted] ប៊ុនសាន បានឆ្លើយថា មិនស្គាល់កូនក្តីខ្លួនទេ ។ នៅថ្ងៃកើតហេតុ កូនក្តីខ្លួននៅខាងក្រៅអង្គុយលើម៉ូតូចាំឈ្មោះ [redacted] ថា ហើយត្រូវគេរុញចូលក្នុងផ្ទះ ហើយគាត់បានបញ្ជាក់ថា ពេលចាប់ខ្លួនដកហូតមានទូរសព្ទ័មួយគ្រឿង និងប្រាក់៩ម៉ឺនរៀល ។ កូនក្តីខ្លួនគ្មានទំនាក់ទំនងជាមួយបទល្មើសទេ តែត្រូវតុលាការថ្នាក់ក្រោមផ្តន្ទាទោសកូនក្តីខ្លួនដាក់ពន្ធនាគារ១០ឆ្នាំច្រើនពេក ។ សុំក្រុមប្រឹក្សាពិនិត្យពិចារណា បើគ្មានពិរុទ្ធភាពសុំដោះលែងបាននៅក្រៅឃុំ ព្រោះគាត់ជាប់ពន្ធនាគារ៣ឆ្នាំទៅ៤ឆ្នាំហើយ សុំរកយុត្តិធម៌ឲ្យគាត់ផង ។

លោក [redacted] ហៃ មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ប៊ុនសាន ផ្តល់សេចក្តីសន្និដ្ឋាន៖

សាលាដំបូងចោទប្រកាន់កូនក្តីខ្លួនពីបទផលិតគ្រឿងញៀន តែពេលចាប់ខ្លួនបានដកហូតថ្នាំញៀនមាន១០០គ្រាប់ ដូច្នេះកំរិតទោសត្រឹមតែ ២ឆ្នាំទៅ៣ឆ្នាំ ប៉ុណ្ណោះ ហើយកូនក្តីខ្លួនបានជាប់ឃុំជិត៨ឆ្នាំហើយ ។ សុំក្រុមប្រឹក្សាសម្រេចតាម មាត្រា៣១ នៃ ច្បាប់គ្រឿងញៀនថ្មី ។

លោក [redacted] វ៉ានឈាន មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ប៊ុនសាន សន្និដ្ឋាន៖

ឈ្មោះ [redacted] ប៊ុនសាន ពេលចាប់ខ្លួនបានដកហូតថ្នាំញៀនមានចំនួន១០០គ្រាប់ប៉ុណ្ណោះ តែសេចក្តីសម្រេចសាលាដំបូងមានការភន្ត័ច្រឡំ ដោយយកកំណត់ហេតុមកចោទ ។ សុំក្រុមប្រឹក្សាធ្វើការជំនុំជំរះលើលិខិត ៩២៨ ត្រូវមាត្រា៣៣.១ នៃច្បាប់គ្រឿងញៀន និងសុំប្តូរបទចោទតាមមាត្រា៣៣.១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនវិញនិងសុំផ្តល់ស្ថានសំរាលទោសតាមមាត្រា៩៣,៩៤ នៃក្រមព្រហ្មទណ្ឌ ដើម្បីគាត់បានទៅជួបជុំក្រុមគ្រួសារ ។

លោក [redacted] ចន្ថា មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ថា និង [redacted] គឹមង៉ុក សន្និដ្ឋាន៖

កូនក្តីខ្លួនឈ្មោះ [redacted] ថា បានឆ្លើយបញ្ជាក់ថា គាត់មិនបានប្រព្រឹត្តទេ ហើយតាមចម្លើយរបស់គាត់នៅសមត្ថកិច្ចគាត់មិនចេះភាសាកម្ពុជាទេ តែចម្លើយនោះគ្មានអ្នកបកប្រែ ។ ផ្ទះឈ្មោះ [redacted] ថា គាត់ជួលគេក្នុងមួយខែ២០០ដុល្លា តាំងពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៧ឡើងក្នុងមួយខែ៣០០ដុល្លា ហើយគាត់បានជួលបន្តឲ្យឈ្មោះ [redacted] យ៉ាហាយ ផ្នែកខាងក្រោម ដោយគាត់ពុំអាចដើរកាត់បាន គឺដើរតាមផ្លូវឡើងហែម ។ ឈ្មោះ [redacted] ប៊ុនសាន បានបញ្ជាក់ថា មិនស្គាល់កូនក្តីខ្លួនទេ តែបើកូនក្តីខ្លួនផលិតគ្រឿងញៀនមែនច្បាស់ជាមានទំនាក់ទំនងគ្នា ឯឈ្មោះ [redacted] សុវណ្ណារ៉ា ថាកូនក្តីខ្លួនគាត់ទិញខោអាវជជុះ ហើយ [redacted] គឹមង៉ុក ក៏ថា មកជួយបត់ខោអាវដែរ ហើយពេលឆែកឆេរបន្ទប់សមត្ថកិច្ចចូលហើយទើបឲ្យកូនក្តីខ្លួនចូលតាមក្រោយ ។ ខ្លួនពិនិត្យឃើញថា ការជួលគ្មានលិខិតស្នាមដោយសារស្គាល់គ្នា រាប់អានគ្នា ហើយកូនក្តីខ្លួនមិនបានធ្វើខុសពីការពិតទេ ។ ចំពោះឧបករណ៍ផលិតគ្រឿងញៀនកូនក្តីខ្លួនបញ្ជាក់ថា ជារបស់ឈ្មោះ [redacted] យ៉ាហាយ និងបក្សពួក ហើយពេលឆែកឆេរអ្នកប្រព្រឹត្តបានរត់ចេញតាមទ្វារក្រោយ។ សុំក្រុមប្រឹក្សាពិចារណាពីហេតុផល និង សុំឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ ។

ដោយឡែកជនជាប់ចោទឈ្មោះ [redacted] គឹមង៉ុក គ្មានហេតុផលសមគំនិតទេ ដូចបញ្ជាក់ក្នុងសវនាការនេះ គ្មានការផ្តល់មធ្យោបាយគ្រាន់តែមកជួយបត់ខោអាវតាមថ្ងៃ គាត់មានអាយុ១៦ឆ្នាំ ពុំមានភស្តុតាងដាក់បន្ទុកទេ សុំឲ្យរួចផុតពីបទចោទ ។

តុលាការអានលទ្ធផលកោសល្យវិច័យលេខ៩២៨/០១០មពអជបគញ ចុះថ្ងៃទី០២-៩-២០១០ លទ្ធផលកោសល្យវិច័យលេខ៩២៩/០១០មពអជបគញចុះថ្ងៃទី០២-៩-២០១០

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៥-០៨-២០១១របស់ជនជាប់ចោទឈ្មោះ [redacted] ថា និង [redacted] គឹមង៉ុក បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៦-០៨-២០១១ របស់ជនជាប់ចោទឈ្មោះ លី សុវណ្ណារ៉ា និងបណ្តឹង /៧



Scanned with CamScanner

ឧទ្ធរណ៍ចុះថ្ងៃទី ១១-០៤-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនសាន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៨ក្រ១ ចុះថ្ងៃទី០៤-០៤-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-នៅថ្ងៃទី ២៧-០៧-២០១០ វេលាម៉ោងប្រហែល១២ថ្ងៃត្រង់ពិតជាមានករណីបង្រ្កាបការជួញដូរគ្រឿងញៀនប្រព្រឹត្តដោយជនជាប់ចោទ ឃី ប៊ុនសាន នៅចំណុចទីតាំងហាងកាហ្វេយូអេនមីប្រាកដមែនតាមវិធីញុះញង់ ទទួលបានថ្នាំញៀនចំនួន១០០គ្រាប់ ស្មើ២៨,១០g តាមកំណត់ហេតុលេខ២០កណហ (ឯកសារលេខ៤)។ បន្ទាប់ពីបង្រ្កាបរួច សមត្ថកិច្ចបានបន្តស្រាវជ្រាវឲ្យជនជាប់ចោទចង្អុលបង្ហាញផ្ទះផលិតនៅចំណុចផ្ទះលេខ៦៦២B ផ្លូវលេខ៣៨៦ សង្កាត់ បឹងកេងកង២ ឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ថា ,[redacted] សុវណ្ណារ៉ា និង [redacted] គឹមង៉ុក ដកហូតបានសំភារៈផលិតថ្នាំញៀនមួយចំនួន , ម្សៅសថ្លា " Ice " ៩៨,៨ក្រាម( Metomphetamin),, ថ្នាំសញ្ញាផ្លែប៉ោម១០៧,៩ក្រាម(MDMA)និងម្សៅដុំពណ៌ស២៧ក្រាម Heroin ,កញ្ចារម៉ត់២៣២ក្រាម ,ថ្នាំសរាងពងក្រពើ២៨១ក្រាម,ម្សៅម៉ត់ពណ៌ស ៤៨២ ,៦០ក្រាម( Ketamin) ។

៣-ជនជាប់ចោទឈ្មោះ [redacted]ប៊ុនសាន បានសារភាពថា បានយកប្រាក់៨.០០០ដុល្លាទៅទិញថ្នាំ១០០គ្រាប់ ប្រគល់ឲ្យអ្នកទិញនៅហាងកាហ្វេយូអេនមីប្រាកដមែន ។ ខ្លួនគ្មានការពាក់ពន្ធ័នឹងការផលិតគ្រឿងញៀននៅផ្ទះលេខ៦៦២Bទេ ។ ខ្លួនស្គាល់ពួកគេតាមរយៈឈ្មោះ ឡេង ដែលស្គាល់ ក្រុមផលិតនេះ និងសុំបន្ធូរបន្ថយទោស។

៤-ជនជាប់ចោទឈ្មោះ [redacted] ថា បានឆ្លើយបដិសេធការចោទប្រកាន់ដោយអះអាងថា ផ្ទះនេះខ្លួនជួលបន្តឲ្យឈ្មោះហាយ, ឈ្មោះ[redacted] និងឈ្មោះង៉ៀង នៅជាន់ក្រោម ក្នុងតម្លៃ៣០០ដុល្លា ប៉ុន្តែមិនបានធ្វើលិខិតលាយលក្ខណ៍អក្សរទេ ។ ពួកគេទាំងបីមិនស្គាល់ទីលំនៅ ហើយខ្លួនអាចចេញចូលជាន់ក្រោមបានដើម្បីដាក់ខោអាវជជុះ ។ ចម្លើយនេះមិនគួរឲ្យជឿបាន ព្រោះគ្មានហេតុផល ដែលជនជាប់ចោទជួលផ្ទះឲ្យអ្នកមិនស្គាល់ទីលំនៅ និងគ្មានអត្តសញ្ញាណច្បាស់លាស់ទេ ពោលគឺពួកគេជាក្រុមរកស៊ីគ្រឿងញៀនជាមួយគ្នា ។

៥-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ា អះអាងថា ខ្លួនគ្មានការពាក់ពន្ធ័នឹងការរកស៊ីគ្រឿងញៀន ប៉ុន្តែខ្លួនមានផ្ទះនៅផ្សារកណ្តាលត្រូវបានឃាត់ខ្លួននៅផ្ទះលេខ៦៦២B គ្មានមូលហេតុដែលត្រូវទិញនំប៉័ង និងមកជូនជនជាប់ចោទទៅជិះឡានក្រុងទៅវៀតណាម ដោយគ្រាន់តែស្គាល់គ្នានោះទេ ។ ដោយឡែកឈ្មោះ [redacted] គឹមង៉ុក អះអាងថា ខ្លួនគ្រាន់តែជាអ្នកដាំស្លប្រោសជូតនិងជួយរើសខោអាវជជុះឲ្យឈ្មោះ [redacted] ថា យកប្រាក់ឈ្នួលតាមថ្ងៃធ្វើការ គ្មានការពាក់ពន្ធ័នឹងការជួញដូរគ្រឿងញៀនទេ ប៉ុន្តែជនជាប់ចោទតែងតែទៅធ្វើការនៅផ្ទះឈ្មោះវិន ថាសំរាកនៅផ្ទះនោះនឹងត្រូវបានឃាត់ខ្លួនជាក់ស្តែងនៅផ្ទះកើតហេតុ អាចជឿបានថា ជាអ្នកសមគំនិត ។

៦-តាមចម្លើយនាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ប៊ុនសាន អះអាងថា ខ្លួនគ្មានការពាក់ពន្ធ័នឹងការផលិតគ្រឿងញៀនទេ គ្រាន់តែទៅទិញយកមកលក់យកប្រាក់ចំណេញ ។ ឈ្មោះ [redacted] ថា ក៏អះអាងថា គ្មានទំនាក់ទំនងជាមួយឈ្មោះ [redacted] ប៊ុនសាន ដែរ គ្រាន់តែធ្លាប់ឃើញមកផ្ទះនេះ ឃើញថាគ្មានភស្តុតាងបញ្ជាក់ថា ឈ្មោះ [redacted] ប៊ុនសាន ស្ថិតនៅក្នុងក្រុមផលិតគ្រឿងញៀនទេ ។/.



Scanned with CamScanner

៧-តាមកំណត់ហេតុទទួលស្គាល់វត្ថុតាងលេខ ០២០ ចុះថ្ងៃទី២៧-៧-២០១០ របស់ឈ្មោះ [redacted] ប៊ុនសាន បញ្ជាក់ថា ថ្នាំដកហូតមាន១០០គ្រាប់ទំងន់សរុប២៨,១០ក្រាម ។ តាមលិខិតកោសល្យវិច័យលេខ ៩២៨/០១០ ចុះថ្ងៃទី០២-៩-២០១១ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀនបានកំណត់ថា ជនជាប់សង្ស័យមានឈ្មោះ [redacted] ប៊ុនសាន, ថ្នាំមានសារធាតុ មេតំហ្វេតាមីន ៤,៤% ស្ថិតនៅក្នុងតារាង II និងកេតតាមីន១៨,៧% ស្ថិតនៅក្នុងតារាង III នៃឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ សរុបមកបរិមាណធាតុសុទ្ធទាំងពីរមុខ ក្នុង១០០គ្រាប់ គឺ: ១៧x២៨,១០( (៤,៤+១៨,៧)= ៦,៤ ក្រាម ។

១០០

៨-តាមលទ្ធផលកោសល្យវិច័យលេខ៩២៩/០១១ចុះថ្ងៃទី ០២-៩-២០១០ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានកំណត់ថា ជនជាប់ពាក់ព័ន្ធឈ្មោះ [redacted] ថា ,[redacted] សុវណ្ណារ៉ា និង [redacted] គឹមង៉ុក មានសំណាកវិជ្ជមាន៥ប្រភេទ គឺ ៖

+សំណាក ក ទំងន់ ៩៤,៨ក្រាម មានសារធាតុសុទ្ធមេតំហ្វេតាមីន ៦៧,៨%=៦៤ក្រាម

+សំណាក ខ ទំងន់១០៧,៩ក្រាមមានសារធាតុសុទ្ធមេតំហ្វេតាមីន ៤,៧ %=៥,០៧ក្រាម និងសារធាតុ កេតមីន២១%=២២,៦៥ក្រាម

+សំណាក ក ទំងន់ ២៧ក្រាម មានសារធាតុសុទ្ធហេរ៉ូអ៊ីន ២០,៤%=៥,៥ក្រាម

+សំណាក ច ទំងន់ ៤៨២ក្រាម មានសារធាតុសុទ្ធកេតាមីន ១៦,៦%=៨០,១១ក្រាម

សរុប=១៧៧,៣៣ ក្រាម

៩-តាមដីកាបញ្ជូនរឿងទៅជំរះលេខ១០០ដជរ ចុះថ្ងៃទី ១២-០១-២០១១ បានបញ្ជូនជនជាប់ចោទឈ្មោះ [redacted]ប៊ុនសាន ទៅជំរះពីបទជួញដូរគ្រឿងញៀនខុសច្បាប់តាមមាត្រា៣៣ថ្មី រីឯជនជាប់ចោទ៣រូបផ្សេងទៀត បញ្ជូនទៅជំរះពីបទជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ និងផលិតគ្រឿងញៀនដែលបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ តាមមាត្រា៣៣ និងមាត្រា ៣២.១ថ្មី ។ សាលក្រមព្រហ្មទណ្ឌលេខ២៨ក្រ១ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចផ្តន្ទាទោសឈ្មោះ [redacted] ប៊ុនសាន ពីបទជួញដូរគ្រឿងញៀនខុសច្បាប់តាមមាត្រា៣៣ថ្មី ហើយពុំបានផ្តន្ទាទោសពីបទផលិតគ្រឿងញៀនទេ ប៉ុន្តែបានសំអាងលើលទ្ធផលកោសល្យវិច័យលេខ៩២៩/០១០ ចុះថ្ងៃទី០២-៩-២០១០ របស់ឈ្មោះ [redacted] ថា ,[redacted] សុវណ្ណារ៉ា និង[redacted] គឹមង៉ុក ដោយមិនបាន សំអាងលើលទ្ធផលកោសល្យវិច័យលេខ៩២៨/០១០ ចុះថ្ងៃទី០២-៩-២០១០ របស់[redacted] ប៊ុនសាន ដែលមានគ្រឿងញៀនតែមួយមុខចំនួន ២៨,១០ក្រាមទេ។

១០-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនសាន មានទំនាក់ទំនងជិតស្និទ្ធជាមួយក្រុមផលិតគ្រឿងញៀនដែលអាចឲ្យជឿថា ធ្លាប់បានជួញដូរញឹកញាប់ គប្បីតុលាការផ្តន្ទាទោសក្នុងកំរិតអតិបរមានៃមាត្រា៣៣.១ ថ្មី ។

១១-ជនជាប់ចោទឈ្មោះ [redacted] គឹមង៉ុក ជាអនីតិជន អាយុ១៦ឆ្នាំ មិនធ្លាប់ត្រូវបានផ្តន្ទាទោស គប្បីតុលាការពិចារណាលើកំរិតអប្បរមាតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ ។

១២-សាលក្រមព្រហ្មទណ្ឌលេខ២៨ក្រ១ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមខាងលើទុកជាបានការ លើកលែងតែចំណុចទី២"ក" និង ចំណុចទី២"ឃ" ដែលត្រូវកែតម្រូវតាមការយល់ឃើញខាងលើ។



Scanned with CamScanner

## <u>មិនិច្ឆ័យសេចក្ដី</u>

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៥-០៤-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ថា និង [redacted] គឹមង៉ុក បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៦-០៤-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ា និង បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១១-០៤-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនសាន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២៤៨ក្រ១ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ លើកលែងតែចំណុចទី២(ក) នៃសេចក្ដីសម្រេច ត្រូវកែប្រែជា

-ចំណុចទី២(ក) ត្រង់" ផ្ដន្ទាទោសឈ្មោះ [redacted] ប៊ុនសាន ដាក់ពន្ធនាគារ១០ឆ្នាំ និងពិន័យជាប្រាក់ចំនួន២០លានរៀល" ត្រូវកែប្រែជា"ផ្ដន្ទាទោសឈ្មោះ [redacted] ប៊ុនសាន ដាក់ពន្ធនាគារ៥ឆ្នាំ ពីបទជួញដូរគ្រឿងញៀនខុសច្បាប់ តាមមាត្រា៣៣.១ថ្មីនៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន" ។

-ចំណុចទី២(ឃ) ត្រង់ " ផ្ដន្ទាទោសឈ្មោះ [redacted] គឹមង៉ុក ដាក់ពន្ធនាគារ៦ឆ្នាំ" ត្រូវកែប្រែជា "ផ្ដន្ទាទោសឈ្មោះ [redacted] គឹមង៉ុក ដាក់ពន្ធនាគារ៥ឆ្នាំ" វិញ ។ ចំណុចដទៃទៀតនៅរក្សាទុកជាបានការដដែល ។

6 – 5ឆ្នាំ

៣-បន្តឃុំខ្លួនជនជាប់ចោទខាងលើតាមនីតិវិធី ។

សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤ ចំពោះមេធាវីការពារជនជាប់ចោទ ជនជាប់ចោទឈ្មោះ [redacted] ថា, [redacted] គឹមង៉ុក, [redacted] សុវណ្ណារ៉ា និងឈ្មោះ [redacted] ប៊ុនសាន និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥-០៣-២០១៤ បើកសិទ្ធិប្ដឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់ ។

សាលដីកានេះចូលជាស្ថាពរលើជនជាប់ចោទឈ្មោះ [redacted] ប៊ុនសាន , ឈ្មោះ [redacted] គឹមង៉ុក និងឈ្មោះ [redacted] សុវណ្ណារ៉ា ។

<u>សេចក្ដីនេះ</u> <u>ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា</u> <u>ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកានិងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះអោយបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់</u> ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី30 ខែមីនា ឆ្នាំ២០១៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]



Scanned with CamScanner